ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៥៥

ចុះថ្ងៃទី៣ខែកក្កដាឆ្នាំ១៩៩៧

<u>សាលដីកា</u>

លេខ : ១៥២

ចុះថ្ងៃទី០៩ខែកក្កដាឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី- ០៩ ខែកក្កដា ឆ្នាំ១៩៩៨ ដោយមានសមាសភាពដូច- តទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ម៉ែន ប៊ុន ជាចៅក្រម

៣- លោក ទៀល មួន ជាចៅក្រម

៤- លោក ស៊ិន ទីម ជាចៅក្រមរបាយការណ៍

៥- លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា ម៉េន សុខា

តំណាងអយ្យការ

លោក ឆ្លូន ស៊ិនមឿង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ១៣៥ ចុះថ្ងៃទី ២៥ ខែមិនា- ឆ្នាំ ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ១៩៩ របស់ សាលាឧទ្ធរណ៍ ។

ដើមបណ្តឹងសាទុក្ខឈ្មោះ អ៊ុំ សុខ ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខ- របរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិម៉ឺនជី ឃុំឆ្លូក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។ ឪពុកឈ្មោះ អ៊ុំ កង "រ" ម្តាយឈ្មោះ នេត ទិក "ស" ។

និងចុងចម្លើយបណ្តឹងសាទុក្ខ អ៊ុំ ឈួន ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរ- បើករថយន្ត ទីលំនៅសព្វថ្ងៃភូមិសិដ្ឋ ឃុំឆ្លូក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។ ឪពុកឈ្មោះ អ៊ុំ ភន "ស" ម្តាយឈ្មោះ "ស" ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំលែងលះ និង សុំចែកទ្រព្យសម្បត្តិ

តាមបណ្តឹងសាទុក្ខលេខ ១.៧៦ ចុះថ្ងៃទី ២២.៥.៩៧ របស់ឈ្មោះ អ៊ុំ សុខ បានប្តឹងមិន សុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ ១៣៥ ចុះថ្ងៃទី២៥.៣.៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៥ ចុះថ្ងៃទី ដ៣.៧.៩៦ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ២៤.២.៩៥ បញ្ជាក់ថា : ខ្លួនប្ដឹងសុំលែងប្រពន្ធ ដោយប្រពន្ធមានចរិកផ្ទុយពីសីលធម៌សង្គម ហើយចេះតែបង្កទំនាស់ជាមួយខ្លួន ។ ចំពោះទ្រព្យរួមគឺផ្ទះក្បឿង ១មាន២ខ្នង ខ្លួនសុំចែកជាពីរស្មើគ្នា ឯទ្រព្យក្រៅពីនេះពុំមានអ្វីទៀតឡើយ ។ ខ្លួនមានកូន២នាក់ ខ្លួនសុំគ្រប់គ្រងកូនច្បង ឯកូនទី២ខ្លួនប្រគល់អោយប្រពន្ធ ។

បានឃើញសាលក្រមលេខ ១១៧ ចុះថ្ងៃទី ២៧.ខែវិច្ឆិកា ឆ្នាំ ១៩៩៥ របស់តុលាការខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ២៤.២.៩៥ របស់ឈ្មោះ អ៊ុំ ឈួន "ដើមចោទ" ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- អោយឈ្មោះ អ៊ុំ ឈួន "ដើមចោទ"និងនារី អ៊ុំ សុខ "ចុងចម្លើយ" ដាច់សហគមសង្វាសពីគ្នាតាមការព្រមព្រៀង ចាប់ពីពេលនេះតទៅ ។

៣- អោយឈ្មោះ នារីអ៊ុំ សុខ "ចុងចម្លើយ"ស្ថិតក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃ គិតថ្ងៃនេះតទៅ ។

៤- កូនបង្កើតពីរនាក់គឺ កូនទី១ឈ្មោះ អ៊ុំ ស៊ីឈួន ស្រី អាយុ១២ឆ្នាំ និងកូនទីពីរឈ្មោះ - អ៊ុំ ស៊ីណាត ស្រី អាយុ៧ឆ្នាំ ត្រូវប្រគល់អោយនារី អ៊ុំ សុខ គ្រប់គ្រង ។ ប៉ុន្តែឈ្មោះ អ៊ុំ ឈួន "ដើមចោទ"ត្រូវជួយចិញ្ចឹមអាហារកិច្ចកូនទាំងពីរនាក់ក្នុងមួយឆ្នាំចំនួន ៦០.០០០រៀល និងចិញ្ចឹមកាយលក្ខភាពបន្ថែមទៀតរហូតដល់កូនទាំងពីរនេះមាននីតិភាព ។

មាតាបិតាមានសិទ្ធិនិងករណីកិច្ចត្រូវអប់រំ ថែទាំចិញ្ចឹមកូន តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

៥- ទុកសិទ្ធិអោយដើមចោទទៅសួរសុខទុក្ខដល់កូនបាន ។

៦- ទ្រព្យសម្បត្តិរួមស៊ីចមានផ្ទះពីរខ្នង ធ្វើពីឈើប្រក់ក្បឿងស្ថិតនៅភូមិស៊ីដី ឃុំឆ្លក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ត្រូវចែកគ្នាស្មើ ។

៧- បង្គាប់អោយឈ្មោះ អ៊ុំ ឈួន "ដើមចោទ" បង់ប្រាក់ប្រដាប់ក្តីសរុប ៧.០០០រៀល ប្រាក់នេះនៅសល់ពីការចំណាយគ្មាន ។ ប្រាក់នេះដើមចោទបានបង់ទុកមុនរួចហើយដែរ ។

តាមបញ្ញត្តិមាត្រា ៩.២៨.៣០.៣៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និងបញ្ញត្តិមាត្រា ៥.៧.៨.១០.១១.១២.១៣.១៤.១៦ នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៨- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកសិទ្ធិប្តឹងឧទ្ធរណ៍កំណត់ ២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ២៤ ចុះថ្ងៃទី ២៩ខែធ្នូ ឆ្នាំ១៩៩៥ របស់ឈ្មោះ អ៊ុំ សុខ ដែលបានប្ដឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ ១១៧ ចុះថ្ងៃទី ២៧.១១.៩៥ របស់តុលាការ-ខេត្តស្វាយរៀងត្រង់ចំណុចទី ៦ ។

បានឃើញសាលដីកាលេខ ១៣៥ ចុះថ្ងៃទី ២៥ ខែមិនា ឆ្នាំ១៩៥៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១_ ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨.១២.៥៥ របស់ឈ្មោះ អ៊ុំ សុខ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២_ តំកល់សាលក្រមលេខ ១១៦ ចុះថ្ងៃទី ២៦.១១.៥៥ របស់តុលាការខេត្តស្វាយ_រៀង ទុកជាបានការពេញទាំងមូល ។

៣_ ទីបង្គាប់ប្រាក់ប្រដាប់ក្តីដាក់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ ក្នុងនោះគឺពន្ធចុះបញ្ជីក្តី និង ពន្ធតែម ២.៥៥០រៀល រង្វាន់ក្រឡា_បញ្ជីការទិបប្រាក់ ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ លើរាជ្យធានាតុលាការ ៥.០០០៛ ។

៤_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ឈ្មោះ អ៊ុំ យួន កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ អ៊ុំ សុខ បើកផ្លូវប្តឹងទាស់និងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១.១៦ ចុះថ្ងៃទី ២២.៥.៥៧ របស់ឈ្មោះ អ៊ុំ សុខ បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ១៣៥ ចុះថ្ងៃទី ២៥.៣.៥៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី០២.៨.៥៧ របស់ឈ្មោះ អ៊ុំ សុខ ។

បានឃើញសារណាតបចុះថ្ងៃទី ១៣.១០.៥៧ របស់ឈ្មោះ អ៊ុំ យួន ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ សាលដីការបស់សាលាឧទ្ធរណ៍លេខ ១៣៥ ចុះថ្ងៃទី ២៥.៣.៥៧ ដែលសំរេចសេចក្តីមកនេះគឺមានលក្ខណៈខុសក្នុងនិងគតិច្បាប់ហើយ ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និង សំរេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អ៊ុំ សុខ ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខដែលបានឆ្លើយនៅពេលសវនាការថា ៖ តុលាការថ្នាក់ក្រោមបានកាត់អោយចែកគ្នាពាក់កណ្តាល ។ ហើយគាត់ចុះចេញពីឆ្នាំ៥២ ទុកអោយខ្លួនចិញ្ចឹមកូនតែម្នាក់ឯង ដោយខ្លួនជំពាក់លុយគេច្រើនពេក ខ្លួនក៏កាត់ផ្ទះនេះសងគេទៅ ហេតុនេះសុំតុលាការកុំកាត់អោយគាត់ពាក់កណ្តាលអី ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អ៊ុំ យួន ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខដែលបានឆ្លើយនៅពេលសវនាការថា ៖ គាត់បាននឹកខ្លួន ហើយសុំខ្លួនវិលឯ ហើយចំពោះការចោទប្រកាន់ថា ខ្លួនលេងល្បែងនេះគឺមិនពិតទេ ខ្លួនទាមទារទ្រព្យសម្បត្តិដែលជាញើសឈាមរបស់ខ្លួនសុំអោយចែកពាក់កណ្តាលដដែល ។ ខ្លួនចុះចេញពីផ្ទះនៅឆ្នាំ ១៩៥៤ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ១៦៦ ចុះថ្ងៃទី ២២.៥.៩៧ របស់អ្នកស្រី អ៊ុំ សុខ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍ ក៏ដូចតុលាការខេត្តស្វាយរៀងដែរដែលសំរេចអោយប្តីប្រពន្ធនេះលែងលះគ្នា និង ប្រគល់កូន២នាក់អោយអ្នកស្រី អ៊ុំ សុខ ចិញ្ចឹមនោះជាការត្រឹមត្រូវហើយ ប៉ុន្តែតុលាការថ្នាក់ក្រោមដែលសំរេចអោយបែងចែកផ្ទះរួមសម្រាប់ជា២ចំណែកស្មើគ្នាដោយពុំបានពិចារណាអំពីការចិញ្ចឹមកូនរបស់អ្នកស្រី អ៊ុំ សុខ នៅពេលដែលលោក អ៊ុំ យួន ចុះចេញពីផ្ទះនោះជាការភ័ន្តច្រឡំពីព្រោះថា តាមមាត្រា ៣៥ ចំណុចទី១ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារដែលកំណត់ថា ការផ្គត់ផ្គង់គ្រួសារ និងចំណាយដើម្បីអប់រំ និង បណ្តុះបណ្តាលកូនត្រូវធ្លាក់លើបន្ទុកទ្រព្យសម្បត្តិរួម ហើយផ្ទះនេះក៏ត្រូវបានអ្នកស្រី អ៊ុំ សុខ លក់ដើម្បីផ្គត់ផ្គង់កូនរួចទៅហើយ ។

- យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ១៣៥ ចុះថ្ងៃទី ២៥.៣.៩៧ របស់សាលាឧទ្ធរណ៍ដែលសំរេចតម្កល់ក្តីនេះមានលក្ខណៈត្រឹមត្រូវ លើកលែងចំណុចទី ៦ នៃសាលក្រមលេខ ១១៧ ចុះថ្ងៃទី ២៧.១១.៩៥ របស់តុលាការខេត្តស្វាយរៀងដែលត្រូវទុកជាមោឃៈ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី ចំពោះមុខក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ១៦៦ ចុះថ្ងៃទី ២២.ខែឧសភា ឆ្នាំ១៩៩៧ របស់អ្នកស្រី អ៊ុំ សុខ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៣៥ ចុះថ្ងៃទី ២៥. ខែមិនា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទុកជាបានការលើកលែងចំណុចទី៦ នៃសាលក្រមលេខ ១១៧ ចុះថ្ងៃទី ២៧ .ខែវិច្ឆិកា ឆ្នាំ ១៩៩៥ របស់តុលាការខេត្តស្វាយរៀងដែលត្រូវទុកជាមោឃៈ ។

៣- បញ្ជូលសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៥ ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ១៩៩៧ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចទី ៦ នៃសាលក្រមលេខ ១១៧ ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ របស់តុលាការខេត្តស្វាយរៀង ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រី អ៊ុំ សុខ បានបង់ទុកនៅតុលាការកំពូលចំនួន ១៥.០០០រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធតែងចំនួន ៥.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់

ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រុមស្រាបញ្ញើការងារពីបព្រាក់

- ចំណាយក្នុងការប្រគល់ស៊ីការកោះចំនួន ១៥.០០០រៀល សរុប - ១៨.០០០រៀល ។

៥- សាលដីការនេះប្រកាសក្នុងសវនាការជាសាធារណៈ នៅថ្ងៃទី ០៩ ខែកក្កដា- ឆ្នាំ ១៩៩៨ ។